ភ្នំពេញ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វឌ្ឍនភាពនៃការកែទម្រង់គោលនយោបាយនិងរដ្ឋបាលសារពើពន្ធ និងកាតព្វកិច្ចពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦"




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:៣០ នាទីព្រឹក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ នៅសណ្ឋាគារ សូហ្វីថែល ភ្នំពេញ ភូគីត្រា មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី " **វឌ្ឍនភាពនៃការកែទម្រង់គោលនយោបាយ និងរដ្ឋបាលសារពើពន្ធ និងកាតព្វកិច្ចពន្ធ លើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦** " ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់ ឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមពីសំណាក់លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាអភិបាល បណ្ណាធិការ តំណាង សហគ្រាស ប្រមាណជាជាង១ 000 សហគ្រាស។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងនូវកិច្ចស្វាគមន៍ និង អំណរគុណចំពោះលោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាអភិបាល បណ្ណាធិការ និងជាតំណាងរោងចក្រ សហគ្រាសនានា ដែលមានវត្តមានចូលរួម នៅក្នុងអង្គសិក្ខាសាលាដ៏មានសារសំខាន់នេះ ដែលនេះជាការសបញ្ជាក់ឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពប្រតិបត្តិច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ជាពិសេស គឺដើម្បីស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួន។ សិក្ខាសាលាដ៏មានសារសំខាន់នេះ នឹងរួមចំណែកខ្ពស់ ក្នុងការពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធ ហើយតាមរយៈសិក្ខាសាលានេះ សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត ស្តីពីកាតព្វកិច្ចពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជម្រាបជូនអង្គសិក្ខាសាលាថា នេះគឺជាសិក្ខាសាលាមួយដ៏មានសារៈសំខាន់ ខណៈដែលរដូវកាល នៃការប្រកាសបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ នឹងត្រូវឈានចូលមកដល់នៅថ្ងៃទី០១ ខែមករា និងត្រូវបិទបញ្ចប់ទៅវិញនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ខាងមុខ។

ក្នុងឱកាសនេះដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជម្រាបជូនអង្គសិក្ខាសាលាឲ្យបានជ្រាប អំពីលទ្ធផលនៃការកែទម្រង់គោលនយោបាយសារពើពន្ធ និង រដ្ឋបាលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលការកែទម្រង់ទាំងនេះ គឺផ្តោតជាសំខាន់លើការកែលម្អ និងបំពេញបន្ថែមនូវបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនៅមានភាពខ្វះចន្លោះ ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ, ការពង្រឹង និងបង្កើនសមត្ថភាពមន្ត្រីពន្ធដារ ធ្វើយ៉ាងណាឲ្យមន្ត្រីរាជការកាន់តែជំនាញ ស្វាហាប់ ពូកែ ស្មោះត្រង់ មានភាពម្ចាស់ការ អនុវត្តការងារប្រកបដោយមនសិការវិជ្ជាជីវៈ សំដៅធានាបាននូវផលិតភាព និង ប្រសិទ្ធភាពការងារ, ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដែលជាស្នូលនៃអភិបាលកិច្ចល្អ និងជាគន្លឹះនៃការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃសេវាសាធារណៈជូនអ្នកជាប់ពន្ធគ្រប់មជ្ឈដ្ឋាន។

ទន្ទឹមនឹងការកែលម្អ និងការពង្រឹងអភិបាលកិច្ច របស់រដ្ឋបាលសារពន្ធ អគ្គនាយកដ្ឋានពន្ធដារក៏បាននិងកំពុងពង្រឹងអនុលោមភាពរបស់អ្នកជាប់ពន្ធផងដែរ សំដៅធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធកាន់តែយល់ច្បាស់ និង ចូលរួមបំពេញកាតព្វកិច្ចពន្ធដោយស្ម័គ្រចិត្ត និងដោយមិនសម្តែងការរអ៊ូរទាំ និងក្នុងន័យទប់ស្កាត់ លុបបំបាត់ការគេចវេះពន្ធ ការលួចបន្លំពន្ធតាមគ្រប់រូបភាព ដើម្បីធានាបាននូវបរិយាកាសធុរកិច្ច និងការប្រកួតប្រជែងដោយស្មើភាពគ្នាចំពោះគ្រប់ធុរជន ក្នុងគោលដៅប្រមូលចំណូលពន្ធ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសមធម៌។

កិច្ចខិតខំប្រឹងប្រែងអនុវត្តគោលនយោបាយនៃការកែទម្រង់ គឺបានស្តែងចេញឲ្យឃើញ តាមរយៈលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធដែលទទួលបានគ្រប់ និងលើសផែនការ ក្នុងរយៈពេល ០៥ ឆ្នាំជាប់ៗគ្នា ចុងក្រោយនេះ ដែលលទ្ធផលទាំងនេះគឺពិតជាមិនអាចកាត់ផ្តាច់បានពីការចូលរួមពីសំណាក់អ្នកជាប់ពន្ធ នោះឡើយ។

ការផ្តល់កិច្ចសហការខ្ពស់ពីសំណាក់អ្នកជាប់ពន្ធ ការគោរព



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិស្តីពីពន្ធដារ គឺជាកិច្ចការចម្បងដែលអ្នកជាប់ពន្ធគ្រប់រូបត្រូវប្រកាន់យក ហើយត្រូវបោះបង់ចោលនូវទម្លាប់ចាស់ ដែលកន្លងមកតែងតែស្នើសុំលើកលែងពន្ធ ដោយលើកយកហេតុផលផ្សេងៗ និងប្រែក្លាយការគោរពប្រតិបត្តិច្បាប់មិនទាន់បានខ្ជាប់ខ្ជួន និងមិនទាន់បានត្រឹមត្រូវឲ្យមកជាការគោរពប្រតិបត្តិច្បាប់ប្រកបដោយខ្ជាប់ខ្ជួន និងត្រឹមត្រូវដោយមកដាក់លិខិតប្រកាស និងបង់ពន្ធឲ្យបានទាន់ពេលវេលា និងឲ្យបានត្រឹមត្រូវ។

មុននឹងបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានផ្តាំផ្ញើដល់សិក្ខាកាមអ្នកជាប់ពន្ធ នូវសារ (Messages)សំខាន់ៗ មួយចំនួនមានជាអាទិ៍ ការពង្រឹងការកាន់កាប់បញ្ជីគណនេយ្យ និងការដាក់របាយការណ៍សវនកម្មហិរញ្ញវត្ថុ, ការតម្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសឲ្យបានគ្រប់ៗសហគ្រាស និង បានទាន់ពេលវេលា, ការពង្រឹង និអនុវត្តតាមការណែនាំការប្រើប្រាស់ភ្នាក់ងារសេវាកម្មពន្ធដារ, ការពង្រឹងការអនុវត្តវិធានការច្បាប់ចំពោះសហគ្រាសដែលផ្គត់ផ្គង់មិនចេញវិក្កយបត្រ ឬបានចេញ វិក្កយបត្រមិនត្រឹមត្រូវ តាមការណែនាំរបស់ អគ្គនាយកដ្ឋានពន្ធដារអំពីវិធានប្រើប្រាស់វិក្កយបត្រ និងការពង្រឹងនិងបង្កើនកិច្ចសហការជាមួយរដ្ឋបាលសារពើពន្ធ ជាពិសេសលើកិច្ចការផ្តល់ឯកសារសម្រាប់ការងារសវនកម្មឲ្យបានត្រឹមត្រូវស្របតាមច្បាប់ បានទាន់ពេលវេលា និងប្រកបដោយតម្លាភាព ព្រមទាំងបន្តផ្តល់កិច្ចសហការខ្ពស់ក្នុងការបង្កើតវប្បធម៌ជជែកពិភាក្សា ផ្តល់យោបល់ផ្តល់ការរិះគន់ក្នុងន័យស្ថាបនាគ្នាទៅវិញទៅមក ដើម្បីអភិវឌ្ឍសមត្ថភាព ទាំងរដ្ឋបាលសារពើពន្ធ ទាំងអ្នកជាប់ពន្ធ ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់យើងទាំងអស់គ្នា នៅក្នុងក្របខ័ណ្ឌនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ ក៏ដូចជាក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក។

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជូនពរឯកឧត្តម-លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី និងសិក្ខាកាមទាំងអស់ សូមសមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរឲ្យអង្គសិក្ខាសាលានាថ្ងៃនេះ ប្រព្រឹត្តទៅប្រកបដោយលទ្ធផលជាផ្លែផ្កា គួរជាទីពេញចិត្ត៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ